## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៖ ០១១ សហវ.

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១១

## សារាចរណែនាំអនុវត្ត
### ប្រកាសលេខ ៣៨៣ សហវ.អពដ.ប្រក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ដើម្បីបង្កើនប្រសិទ្ធភាពទប់ស្កាត់ការប្រឈមរាល់អំពើអសកម្ម និងវិច្ឆេទកម្ម ដែលនាំដល់ការរិះគន់ពីម្ចាស់យានយន្ត និងជាពិសេសក្នុងគោលបំណងពង្រឹងអភិបាលកិច្ចនៅក្នុងអគ្គនាយកដ្ឋានពន្ធដារឱ្យកាន់តែល្អថែមទៀត ស្របតាមប្រកាសលេខ ៣៨៣ សហវ.អពដ.ប្រក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមកំណត់ណែនាំអនុវត្ត ដូចខាងក្រោម ៖

**I- អំពីភារកិច្ចរបស់ម្ចាស់យានយន្ត ៖**

ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់ និងទប់ស្កាត់ការចំណាយមិនចាំបាច់ក្នុងការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១១នេះ ម្ចាស់យានយន្តត្រូវបំពេញកាតព្វកិច្ច ដូចខាងក្រោម ៖

១. ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១១ រហូតដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ឱ្យបានទាន់ពេលវេលា ។

២. ការដាក់លិខិតប្រកាស និងបង់ពន្ធ ៖
- ចំពោះរថយន្ត ម្ចាស់យានយន្តត្រូវសរសេរបំពេញលិខិតប្រកាសដោយខ្លួនឯង ចំនួន ០២ ច្បាប់ ដែលមានតម្លៃស្មើ ៤០០រៀល និងបង់ពន្ធតាមច្បាប់កំណត់ ដោយភ្ជាប់មកជាមួយនូវបង្កាន់ដៃបង់ពន្ធឆ្នាំ២០១០
- ចំពោះទោចក្រយានយន្ត និងត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រូវទិញបណ្ណបង់ពន្ធ ដោយពុំចាំបាច់បំពេញលិខិតប្រកាសឡើយ។

៣. ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធដោយផ្ទាល់ នៅតាមប៉ុស្តិ៍ (ទីសំចត) ឬស្នាក់ការពន្ធដារ ឬសាខាពន្ធដារ ដែលសម្រេចដោយអាជ្ញាធរដែនដីរាជធានី-ខេត្ត ដើម្បីទប់ស្កាត់ការកើតឡើងនូវតម្លៃលើស ឬទិញបណ្ណក្លែងក្លាយ ។

៤. ត្រូវសហការជាមួយភ្នាក់ងារពន្ធដារ ឬសមត្ថកិច្ចនានា ឬអាជ្ញាធរដែនដី ក្នុងករណីពិនិត្យឃើញមានការបង់ពន្ធលើស ឬលក់បណ្ណបង់ពន្ធក្លែងក្លាយ ។

៥. លោក-លោកស្រី ជាម្ចាស់យានយន្ត ឬអាជ្ញាធរដែនដី ឬអង្គការសង្គមស៊ីវិល អាចផ្តល់មតិរិះគន់ដោយត្រូវដាក់លិខិតក្នុងប្រអប់សំបុត្រនៅសាខាពន្ធដារខេត្ត ឬទីស្នាក់ការប្រមូលពន្ធ ក្នុងករណីពិនិត្យឃើញថា មានការទារពន្ធលើស ឬភាពមិនច្បាស់លាស់ ឬអំពើវិច្ឆេទកម្មផ្សេងៗ ដូចជា ៖ មានលក់បណ្ណក្លែងក្លាយ ធ្វើឱ្យមានភាពចលាចលដែលនាំឱ្យបាត់បង់ថវិកាជាតិ និងភាពអសកម្មនានា ក្នុងការប្រមូលពន្ធ ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរសព្ទ៍ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

**II- អំពីភារកិច្ចរបស់ភ្នាក់ងារពន្ធដារ ៖**

ភ្នាក់ងារពន្ធដារដែលមានភារកិច្ចប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១១ ត្រូវអនុវត្ត ដូចខាងក្រោម ៖

១. ត្រូវស្លៀកពាក់ឯកសណ្ឋានពន្ធដារក្នុងពេលម៉ោងធ្វើការ

២. ត្រូវមានសីលធម៌ល្អ សុភាពរាបសារ និងហ្មឹងម៉ាត់ក្នុងការងារ

៣. ត្រូវគោរពពេលម៉ោងធ្វើការឱ្យបានទៀងទាត់គឺ ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ និងថ្ងៃសៅរ៍-អាទិត្យ តាមសំណូមពររបស់រដ្ឋបាលរាជធានី-ខេត្ត ក្នុងករណីចាំបាច់ ៖

- ព្រឹក ៖ ពីម៉ោង ៨:៣០ ដល់ម៉ោង ១១:៣០
- រសៀល ៖ ពីម៉ោង ១៤:០០ ដល់ម៉ោង ១៦:៣០

ដោយហេតុថា ពេលព្រឹកត្រូវបើកឯកសារ និងពេលរសៀល ត្រូវទូទាត់ប្រាក់ពន្ធដែលប្រមូលបានចូលក្នុងបេឡា ។

៤. នៅតាមប៉ុស្តិ៍ (ទីសំចត) ស្នាក់ការពន្ធដារ សាខាពន្ធដារ ភ្នាក់ងារពន្ធដារត្រូវរៀបចំកន្លែងធ្វើការឱ្យបានសមរម្យ និងមានបំពាក់សំភារៈ ដូចតទៅ ៖

- ចងផ្ទាំងក្រណាត់ទំហំ ០,៦០ម x ៤ម និងបោះពុម្ពខិតបណ្ណផ្សព្វផ្សាយអំពីព័ត៌មានក្នុងយុទ្ធនាការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ
- នៅទីតាំងប្រមូលពន្ធ ត្រូវបិទតារាងតម្លៃប្រាក់ពន្ធ តម្លៃលិខិតប្រកាស និងព័ត៌មានផ្សេងៗទៀតដែលទាក់ទិនទៅនឹងការប្រមូលពន្ធ ដើម្បីឱ្យម្ចាស់យានយន្តអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់កំណត់ ។

៥. ភ្នាក់ងារពន្ធដារមិនត្រូវទារ ឬទទួលប្រាក់លើសពីការលក់ឯកសារ ឬប្រាក់កម្រៃពីការសរសេរបង្កាន់ដៃបង់ពន្ធ ទោះស្ថិតក្នុងរូបភាពណាក៏ដោយ ។ ទន្ទឹមនឹងនេះ ភ្នាក់ងារពន្ធដារត្រូវត្រៀមសាច់ប្រាក់តាមប្រភេទ ដើម្បីទូទាត់ (អាប់) ជូនម្ចាស់យានយន្តដោយភាពត្រឹមត្រូវ ។

៦. នៅតាមសាខាពន្ធដារខេត្ត និងនៅទីស្នាក់ការពន្ធដារស្រុកនីមួយៗ ភ្នាក់ងារពន្ធដារត្រូវរៀបចំប្រអប់សំបុត្រមានចាក់សោ ដើម្បីទទួលព័ត៌មានផ្សេងៗជាយថាហេតុ ។ ប្រអប់សំបុត្រនេះត្រូវបើកជារៀងរាល់ថ្ងៃហើយរាយការណ៍ជូនប្រធានអង្គភាពសាមី ដើម្បីដោះស្រាយ ។

**III- កិច្ចសហការ ៖**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំណូមពរដល់អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងអង្គការសង្គមស៊ីវិល ជួយសហការក្នុងការប្រមូលពន្ធនេះឱ្យមានប្រសិទ្ធភាព និងតម្លាភាព ៖

១. ជួយណែនាំពន្យល់ និងផ្សព្វផ្សាយអំពីប្រកាស សេចក្តីជូនដំណឹង សារាចរណែនាំអនុវត្តស្តីពីពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១១ ដល់ម្ចាស់យានយន្តឱ្យបានយល់ច្បាស់អំពីកាតព្វកិច្ចរបស់ខ្លួនឱ្យបានរួសរាន់ទាន់ពេលវេលា ជៀសវាងកកកុំ ប្រមូលផ្តុំមកបង់ពន្ធនៅថ្ងៃផុតកំណត់

២. រក្សានូវសមភាពភាព មិនលំអៀង ដោយគតិបណ្ឌិត និងយុត្តិធម៌

៣. ជួយពិនិត្យ តាមដាន ឃ្លាំមើល និងផ្តល់ព័ត៌មានមកអគ្គនាយកដ្ឋានពន្ធដារពីប្រភពផលិត និងប្រើប្រាស់ឯកសារក្លែងក្លាយ ដើម្បីឃាត់ខ្លួនជនប្រព្រឹត្តបទល្មើសមកផ្តន្ទាទោសតាមច្បាប់ ។

អគ្គនាយកដ្ឋានពន្ធដារ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ តាមភារកិច្ចរៀងៗខ្លួន ត្រូវចាត់ចែងអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃសារាចរនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់សាលារាជធានី-ខេត្ត
- អគ្គនាយកដ្ឋានពន្ធដារ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ